# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
"រ.ទ.ស.ភ"
លេខ ២០៨.ស.ភ.ល

## សេចក្តីជូនដំណឹង
## ស្តីពី កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៩ អាណត្តិទី៥
## របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា នៅ **ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ វេលាម៉ោង១៤:០០នាទីរសៀល** រ.ទ.ស.ភ នឹងរៀបចំកិច្ចប្រជុំសាមញ្ញ លើកទី១៩ របស់ក្រុមប្រឹក្សាភិបាល អាណត្តិទី៥ នៃ រ.ទ.ស.ភ នៅទីចាត់ការប្រតិបត្តិនៃ រ.ទ.ស.ភ ដែលមានរបៀបវារៈដូចខាងក្រោម៖

១. របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៤ ឆ្នាំ២០១៥

២. របាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៥

៣. របាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០១៥

៤. របាយការណ៍ស្តីពីលទ្ធផលការងារ១០ខែ បូក២ខែប៉ាន់ស្មានឆ្នាំ២០១៥ និងផែនការត្រីមាសទី១ ឆ្នាំ២០១៦

៥. សំណើសុំគោលការណ៍លុបចេញពីបញ្ជីឆ្នាំ២០១៥ នូវអចលនទ្រព្យខូច-បាត់បង់គុណភាព និងធ្វើសំវិធានធនសន្និធិឃ្លាំង នូវសម្ភារមិនប្រើប្រាស់ និងប្រកាសលក់ឡាយឡុង

៦. សំណើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុញ្ញាតឱ្យ រ.ទ.ស.ភ បានរួចអាករលើតម្លៃបន្ថែម(VAT) នូវរាល់ការផ្គត់ផ្គង់ទំនិញ និងសេវាសាងសង់ក្នុងស្រុក សម្រាប់គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធជំហានទី២ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍

៧. សំណើសុំពិនិត្យ-សម្រេចលើគោលការណ៍ផាកពិន័យរាល់ការខូចខាតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ រ.ទ.ស.ភ

៨. សំណើសុំពិនិត្យ-សម្រេចលើអាណត្តិ របស់អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងអភិបាលឯករាជ្យ ជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រ.ទ.ស.ភ

៩. កិច្ចពិភាក្សាស្តីពីការបង្កើតគណៈកម្មាធិការវិនិយោគរបស់ក្រុមប្រឹក្សាភិបាល

១០. សំណើសុំពិនិត្យ-សម្រេចលើគោលការណ៍វិនិយោគទិញម៉ាស៊ីនភ្លើងសម្រាប់ដំណើរការរោងចក្រផលិតទឹកស្អាត

១១. ផ្សេងៗ

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនជ្រាប។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**